Khmer | ខ្មែរ

# ករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (DUTY OF CANDOUR)



## សំណួរដែលគេតែងសួរជាញឹកញាប់

### ? តើអ្វីជាគ្រោះថ្នាក់ខ្លាំង?

**A** គ្រោះថ្នាក់ខ្លាំងគឺជាព្រឹត្តិការណ៍សុវត្ថិភាពអ្នកជំងឺរងផលប៉ះពាល់ធ្ងន់ធ្ងរ **(SAPSE)** ហើយជាព្រឹត្តិការណ៍មួយដែល៖

- បានកើតឡើងខណៈពេលដែលអ្នកជំងឺកំពុងទទួលការថែទាំពីសេវាកម្មសុខភាព និង
- បាននាំមកនូវលទ្ធផលដោយអចេតនា ឬមិនបានរំពឹងទុក
  - **គ្រោះថ្នាក់កម្រិតមធ្យម៖** គឺនៅពេលដែលតម្រូវការព្យាបាលកម្រិតមធ្យមកើនឡើង ដូចជាការត្រឡប់ទៅការវះកាត់វិញដោយមិនបានគ្រោងទុក ឬមិនបានរំពឹងទុក ប៉ុន្តែមិនមែនជាការខូច ឬរបួសជាអចិន្ត្រៃយ៍ចំពោះមនុស្សនោះទេ។ នេះអាចមិនរាប់បញ្ចូលករណីទាំងឡាយដែលភាពស្មុគស្មាញបានកើតឡើងដែលបានពន្យល់ក្នុងអំឡុងពេលដំណើរការយល់ព្រមនោះទេ។
  - **គ្រោះថ្នាក់ធ្ងន់ធ្ងរ/ស្លាប់៖** បណ្ដាលឱ្យមានការថយចុះមុខងារជាអចិន្ត្រៃយ៍ដល់មនុស្សម្នាក់ ដែលមិនមែនជាផ្នែកនៃជំងឺ ឬស្ថានភាពរបស់មនុស្សនោះទេ។ គ្រោះថ្នាក់នោះអាចបណ្ដាលឱ្យមានភាពជាអចិន្ត្រៃយ៍ ឬស្លាប់។
  - **គ្រោះថ្នាក់ដល់ផ្លូវចិត្តរយៈពេលយូរ៖** គឺជាគ្រោះថ្នាក់ផ្លូវចិត្តដែលមនុស្សម្នាក់បានជួបប្រទះ ឬទំនងជាជួបប្រទះ សម្រាប់រយៈពេលជាបន្តយ៉ាងហោចណាស់ 28 ថ្ងៃបន្ទាប់ពីព្រឹត្តិការណ៍មិនល្អមួយ។

### ? តើនរណាជាអ្នកសម្រេចថាព្រឹត្តិការណ៍នោះត្រូវបានចាត់ថ្នាក់ថាជាគ្រោះថ្នាក់ខ្លាំងឬអត់?

**A** សម្រាប់ព្រឹត្តិការណ៍មួយដែលត្រូវបានចាត់ថ្នាក់ថាជាគ្រោះថ្នាក់ខ្លាំង (ឬ **SAPSE**) វាត្រូវតែបំពេញតាមលក្ខណៈវិនិច្ឆ័យខាងលើដូចដែលបានកំណត់ដោយអ្នកអនុវត្តសុខភាពដែលបានចុះបញ្ជីស្របច្បាប់ (ដូចជាគិលានុបដ្ឋាកដែលបានចុះបញ្ជីស្របច្បាប់)។

ពេលខ្លះរឿងនេះអាចមានភាពស្មុគស្មាញណាស់។ ពេលខ្លះសេវាកម្មសុខភាពដឹងអំពីគ្រោះថ្នាក់ខ្លាំងតាមមធ្យោបាយផ្សេងទៀត ឬនៅពេលក្រោយមកទៀតផងដែរ ដូចជាតាមរយៈពាក្យបណ្ដឹងពីខាងក្រៅ ឬពីតុលាការអ្នកពិនិត្យសាកសពរដ្ឋវិចថូរៀ (Coroners Court of Victoria)។

### ? តើអ្វីទៅជាករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candour)?

**A** ករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម **(Duty of Candor)** គឺជាដំណើរការមួយដែលសេវាកម្មសុខភាពនឹងមានការទទួលខុសត្រូវក្នុងការផ្ដល់ជូនអ្នក និង/ឬគ្រួសារ ឬអ្នកថែទាំរបស់អ្នកជាមួយនឹងចំណុចដូចខាងក្រោម នៅពេលគ្រោះថ្នាក់ខ្លាំងកើតមានឡើង៖

1. ការសុំទោស
2. អង្គហេតុនៃព្រឹត្តិការណ៍ - មានន័យថាអ្វីដែលបានកើតឡើង និងមូលហេតុ។ នេះអាចរួមមានតារាងពេលវេលាដែលនាំទៅដល់ព្រឹត្តិការណ៍នោះ
3. ការឆ្លើយតបរបស់សេវាកម្មសុខភាពចំពោះព្រឹត្តិការណ៍នោះ - មានន័យថាអ្វីខ្លះដែលសេវាកម្មសុខភាពបានធ្វើនៅចំពេល និងក្រោយព្រឹត្តិការណ៍នោះ
4. ជំហាននានាដែលកំពុងត្រូវបានធ្វើឡើង ដើម្បីបង្ការកុំឱ្យព្រឹត្តិការណ៍ស្រដៀងគ្នានេះកើតឡើងម្ដងទៀត

រឿងនេះតម្រូវឱ្យផ្ដល់ជូនអ្នកក្នុងទម្រង់ជារបាយការណ៍មួយ។

### ? តើអ្នកណានឹងចូលរួមក្នុងកិច្ចប្រជុំករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀមដំបូង (Duty of Candor) និងការពិនិត្យសើរើឡើងវិញនៃព្រឹត្តិការណ៍ផងដែរនោះ?

**A** កិច្ចប្រជុំករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម **(Duty of Candor)** និងការពិនិត្យសើរើឡើងវិញអាចកើតឡើងក្នុងពេលតែមួយ ដូច្នេះមិនមែនព័ត៌មានទាំងអស់អាចត្រូវបានគេដឹងនៅពេលនៃកិច្ចប្រជុំដំបូងនោះទេ។

សេវាកម្មសុខភាពអាចមានមនុស្សចម្រុះនៅក្នុងកិច្ចប្រជុំជាមួយអ្នក និង/ឬគ្រួសារ ឬអ្នកថែទាំរបស់អ្នក។ នេះអាចរួមបញ្ចូលមនុស្សទាំងឡាយដូចជាគ្រូពេទ្យគ្លីនិកជាន់ខ្ពស់ដែលពាក់ព័ន្ធនឹងការថែទាំរបស់អ្នក និងសមាជិកនៃក្រុមអភិបាលកិច្ចគ្លីនិក ហើយនឹងជាឱកាសសម្រាប់អ្នកដើម្បីសួរសំណួរណាមួយដែលអ្នកអាចមាន។

ដើម្បីយល់ឱ្យបានច្បាស់អំពីអ្វីដែលបានកើតឡើង សេវាកម្មសុខភាពក៏នឹងប្រមូលផ្ដុំមនុស្សមួយក្រុមជាមួយគ្នា ដើម្បីស៊ើបអង្កេតដោយឯករាជ្យពីមូលហេតុដែលគ្រោះថ្នាក់នោះបានកើតឡើង។

ដើម្បីធានាបាននូវឯករាជ្យភាពរបស់ខ្លួន សមាជិកនៃក្រុមពិនិត្យសើរើឡើងវិញនឹងមិនត្រូវបានឱ្យចូលរួមដោយផ្ទាល់នៅក្នុងព្រឹត្តិការណ៍ដែលបណ្ដាលឱ្យមានគ្រោះថ្នាក់នោះទេ ប៉ុន្តែនឹងសម្ភាសជាមួយអស់អ្នកដែលធ្លាប់ជាប់ពាក់ព័ន្ធនឹងព្រឹត្តិការណ៍នោះ។ មតិកែលម្អរបស់អ្នកនឹងមានតម្លៃចំពោះដំណើរការនៃការពិនិត្យសើរើឡើងវិញ ដូច្នេះសូមសួរមនុស្សទំនាក់ទំនងចម្បង ឬមន្ត្រីទំនាក់ទំនងអ្នកប្រើប្រាស់របស់អ្នក អំពីរបៀបដែលអ្នកអាចចូលរួមបាន។

### ? តើតួនាទីរបស់មនុស្សទំនាក់ទំនងចម្បង ឬមន្ត្រីទំនាក់ទំនងអ្នកប្រើប្រាស់មានអ្វីខ្លះ?

**A** សេវាកម្មសុខភាពនឹងផ្ដល់ឱ្យអ្នកនូវព័ត៌មានលម្អិតអំពីមនុស្សទំនាក់ទំនងចម្បង ឬមន្ត្រីទំនាក់ទំនងអ្នកប្រើប្រាស់។

បុគ្គលនេះនឹងក្លាយជាអ្នកទំនាក់ទំនងចម្បងរបស់អ្នកពីសេវាកម្មសុខភាពខណៈពេលដែលកំពុងឆ្លងកាត់ដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor)។ ប្រសិនបើអ្នកមានសំណួរ ឬកង្វល់ណាមួយ អ្នកគួរតែនិយាយជាមួយពួកគេជាមុនសិន។

# ករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (DUTY OF CANDOUR)

## សំណួរដែលគេតែងសួរជាញឹកញាប់

## សិទ្ធិរបស់អ្នក

### ចុះប្រសិនបើខ្ញុំត្រូវការជំនួយដើម្បីចូលរួមក្នុងដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor)?

អ្នកអាចតែងតាំងសមាជិកគ្រួសារ ឬអ្នកថែទាំម្នាក់ ឬអ្នកដែលត្រូវបានតែងតាំងផ្សេងទៀត ដើម្បីនៅជាមួយអ្នកពេញទូទាំងដំណើរការនេះ។

សេវាកម្មសុខភាពក៏គួរតែផ្តល់ជូនអ្នកនូវមនុស្សទំនាក់ទំនងចម្បង ឬមន្ត្រីទំនាក់ទំនងអ្នកប្រើប្រាស់ ដែលអាចជួយអ្នកក្នុងដំណើរការនេះ ដោយឆ្លើយសំណួរណាមួយដែលអ្នកអាចមានផងដែរ។

### តើការគាំទ្រអ្វីខ្លះដែលខ្ញុំអាចចូលប្រើបាន?

អ្នកគួរតែទាក់ទងជាមួយសេវាកម្មសុខភាពរបស់អ្នក ប្រសិនបើអ្នកគិតថាអ្នកអាចត្រូវការអ្វីមួយដូចខាងក្រោម៖

- អ្នកបកប្រែភាសាសរសេរ
- អ្នកបកប្រែភាសាផ្ទាល់មាត់
- ទីប្រឹក្សា
- ការទូទាត់នៃការចំណាយចេញពីហោប៉ៅ សម្រាប់អ្វីៗដូចជាការដឹកជញ្ជូន ចំណតរថយន្ត អាហារ។

ជាផ្នែកនៃដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor) អ្នកនឹងត្រូវបានផ្តល់ឱ្យនូវមនុស្សទំនាក់ទំនងចម្បង ឬមន្ត្រីទំនាក់ទំនងអ្នកប្រើប្រាស់ ដើម្បីជួយអ្នកក្នុងដំណើរការនេះ។

### តើខ្ញុំអាចសម្រេចចិត្តបានទេថាអ្នកណានឹងត្រូវ ហើយមិនត្រូវចូលរួមក្នុងកិច្ចប្រជុំករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor)?

អ្នកអាចណែនាំអ្នកណាដែលអ្នកចង់ ឬមិនចង់ឱ្យមានវត្តមាននៅក្នុងអំឡុងពេលកិច្ចប្រជុំករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor) បាន។ នេះរួមមាន៖

- ការសម្រេចចិត្តថាតើអ្នកចង់នាំមនុស្សគាំទ្រមកជាមួយអ្នកឬអត់
- ការស្នើសុំថា**មិនឱ្យ**បុគ្គលជាក់លាក់ម្នាក់ចូលរួមការពិនិត្យសើរើឡើងវិញ ប្រសិនបើការនេះធ្វើឱ្យអ្នកមានទុក្ខព្រួយ។

### តើខ្ញុំនឹងរួមចំណែកក្នុងកិច្ចប្រជុំករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor) និងការពិនិត្យសើរើឡើងវិញព្រឹត្តិការណ៍នោះដោយរបៀបណា?

អ្នកសម្រេចចិត្តថាតើអ្នកចង់រួមវិភាគទានប៉ុន្មានទៅក្នុងការពិនិត្យសើរើឡើងវិញ។ កិច្ចការមួយចំនួនដែលអ្នកអាចធ្វើបាន រួមមាន៖

- មុនពេលកិច្ចប្រជុំ អ្នកអាចកត់ត្រា/សរសេរទុក៖
  - ពីអ្វីខ្លះដែលអ្នកចងចាំអំពីព្រឹត្តិការណ៍នោះ ឬប្រសិនបើព្រឹត្តិការណ៍នោះប៉ះពាល់ដល់អ្នកផ្សេងទៀត អ្វីខ្លះដែលពួកគេប្រហែលជាបានប្រាប់អ្នក
  - រាល់សំណួរណាមួយដែលអ្នកមានអំពីអ្វីដែលបានកើតឡើង អ្វីខ្លះដែលបានដំណើរការទៅខុស និងផលប៉ះពាល់អ្វីខ្លះដែលមានចំពោះអ្នក/សមាជិកគ្រួសាររបស់អ្នក
  - របៀបដែលអ្នកអាចចូលរួមក្នុងដំណើរការពិនិត្យសើរើឡើងវិញ
  - អ្វីផ្សេងទៀតដែលអ្នកចង់ឱ្យអ្នកត្រួតពិនិត្យសើរើឡើងវិញដឹង
- ក្នុងអំឡុងពេលកិច្ចប្រជុំ អ្នកអាចចែករំលែកគំនិត និងបទពិសោធន៍របស់អ្នក ហើយអ្នកអាចសួរសំណួរណាមួយដែលអ្នកចង់ ដើម្បីជួយធ្វើឱ្យយល់ដឹងអំពីអ្វីដែលបានកើតឡើង
- អ្នកអាចពិនិត្យសើរើឡើងវិញនូវកំណត់ត្រាកិច្ចប្រជុំករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor) ក្រោយកិច្ចប្រជុំ ហើយផ្តល់មតិកែលម្អប្រសិនបើចាំបាច់។ កំណត់ត្រាទាំងនេះមានអ្វីគ្រប់យ៉ាងដែលបានពិភាក្សានៅក្នុងកិច្ចប្រជុំ
- នៅចុងបញ្ចប់នៃការពិនិត្យសើរើឡើងវិញនៃព្រឹត្តិការណ៍នោះ អ្នកក៏នឹងទទួលបានរបាយការណ៍ចុងក្រោយដែលបង្ហាញពីរបកគំហើញ និងការកែលម្អនានាណាមួយ។ អ្នកនឹងអាចពិនិត្យសើរើឡើងវិញលើចំណុចនេះ ហើយគួរទាក់ទងទៅសេវាកម្មសុខភាព ប្រសិនបើអ្នកមានសំណួរណាមួយ។

# ករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (DUTY OF CANDOUR)

## សំណួរដែលគេតែងសួរជាញឹកញាប់

## សិទ្ធិរបស់អ្នក

### ? ចុះបើខ្ញុំមិនចង់មានកិច្ចប្រជុំនៅឯមន្ទីរពេទ្យ/សេវាកម្មសុខភាពដែលគ្រោះថ្នាក់បានកើតឡើង?

**A** អ្នកអាចសម្រេចចិត្តពីរបៀបដែលអ្នកចង់ចូលរួមកិច្ចប្រជុំនោះ - តាមរយៈទូរសព្ទ ការហៅទូរសព្ទតាមវីដេអូ នៅមន្ទីរពេទ្យ ឬនៅទីកន្លែងផ្សេងជំនួសវិញ ប្រសិនបើសេវាកម្មមានសមត្ថភាពនឹងធ្វើដូចនោះបាន។

### ? តើខ្ញុំអាចសម្រេចចិត្តមិនចូលរួមក្នុងករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor) បានទេ?

**A** អ្នកអាចសម្រេចចិត្តជ្រើសយកការមិនចូលរួម ឬមិនចូលរួមក្នុងដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម **(Duty of Candor)** បាន។

ប្រសិនបើអ្នកសម្រេចចិត្តធ្វើបែបនេះ សេវាកម្មសុខភាពនឹងស្នើសុំឱ្យអ្នកចុះហត្ថលេខាលើសេចក្ដីថ្លែងការណ៍មួយដើម្បីចូលជាធរមាន។ ពួកគេក៏នឹងផ្ដល់ឱ្យអ្នកនូវព័ត៌មានលម្អិតអំពីមនុស្សទំនាក់ទំនងចម្បង ឬមន្ត្រីទំនាក់ទំនងអ្នកប្រើប្រាស់ សម្រាប់ការទំនាក់ទំនងនាពេលអនាគត។

**ដឹងថាអ្នកអាចផ្លាស់ប្ដូរចិត្តនៅពេលក្រោយក៏បានដែរ។** ប្រសិនបើអ្នកផ្លាស់ប្ដូរចិត្តរបស់អ្នក សូមនិយាយទៅកាន់មនុស្សទំនាក់ទំនងចម្បង ឬមន្ត្រីទំនាក់ទំនងអ្នកប្រើប្រាស់នៅឯសេវាកម្មសុខភាព ដើម្បីចាប់ផ្ដើមដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor)។

### ? ចុះប្រសិនបើខ្ញុំមិនទាន់ត្រៀមខ្លួនរួចរាល់ក្នុងការចូលរួមក្នុងដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor)?

**A** អ្នកអាចស្នើសុំការពន្យារពេលចំពោះករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម **(Duty of Candor)** ជាពិសេសប្រសិនបើអ្នកកំពុងពុះពារតស៊ូជាមួយការបាត់បង់មនុស្សជាទីស្រឡាញ់ម្នាក់។ សេវាកម្មសុខភាពនឹង៖

- ស្វែងរកកាលបរិច្ឆេទដែលអាចយល់ព្រមព្រៀងគ្នាសម្រាប់សេវាកម្មសុខភាពទាក់ទងមកអ្នក ឬ
- ផ្ដល់ឱ្យអ្នកនូវព័ត៌មានទំនាក់ទំនងលម្អិតសម្រាប់មនុស្សទំនាក់ទំនងចម្បង ឬមន្ត្រីទំនាក់ទំនងអ្នកប្រើប្រាស់ ដូច្នេះអ្នកអាចទាក់ទងទៅពួកគេបាននៅពេលអ្នករួចរាល់ហើយ។

### ? តើដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor) អាចនឹងត្រូវពន្យារនៅពេលណា?

**A** ប្រសិនបើអ្នកបានបាត់បង់សមត្ថភាពក្នុងការចូលរួមដោយសារតែគ្រោះថ្នាក់ ឬមិនអាចចូលរួមផ្នែកវេជ្ជសាស្ត្រនៅក្នុងករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម **(Duty of Candor)** ពេលនោះដំណើរការនេះអាចបន្តជាមួយគ្រួសារសាច់ញាតិជិតស្និទ្ធ អ្នកថែទាំញាតិសន្តានបន្ទាប់របស់អ្នក ឬអ្នកដែលអាចតែងតាំងអ្នកតំណាងផ្ទាល់ខ្លួនរបស់អ្នកក៏បានដែរ។

នៅពេលអ្នកជាសះស្បើយឡើងវិញ ដោយមិនគិតពីថាតើករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor) បានកើតឡើងឬអត់នោះទេ ជាមួយបុគ្គលដែលបានតែងតាំងរបស់អ្នក សេវាកម្មសុខភាពនឹងចាប់ផ្ដើមដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor) ម្ដងទៀតជាមួយអ្នក (លុះត្រាតែអ្នកមិនមានបំណងចង់ចូលរួម ដោយសម្រេចជ្រើសយកការមិនចូលរួម)។

### ? ចុះប្រសិនបើសេវាកម្មសុខភាពមិនបានកំណត់អត្តសញ្ញាណគ្រោះថ្នាក់ខ្លាំងទេ តើខ្ញុំអាចចាប់ផ្ដើមដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor) បានទេ?

**A** ប្រសិនបើអ្នកជឿជាក់ថាអ្នកបានជួបប្រទះគ្រោះថ្នាក់ខ្លាំងពីសេវាកម្មសុខភាព ប៉ុន្តែសេវាកម្មនោះមិនបានចាប់ផ្ដើមដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម **(Duty of Candor)** ទេ អ្នកគួរតែស្នើសុំនិយាយជាមួយសមាជិកនៃបុគ្គលិក ឬមន្ត្រីទំនាក់ទំនងអ្នកប្រើប្រាស់។

បន្ទាប់មក សេវាកម្មសុខភាពនឹងពិនិត្យសើរើឡើងវិញនូវគ្រោះថ្នាក់ដែលអាចកើតមានដែលអ្នកបានជួបប្រទះ ដើម្បីពិនិត្យមើលថាតើវាសមស្របនឹងលក្ខណៈវិនិច្ឆ័យដែរឬទេ។ ប្រសិនបើវាមិនដូច្នោះទេ អ្នកប្រហែលជានៅតែជាប់ជំពាក់នឹងការលាតត្រដាងដោយបើកចំហ ដូចដែលបានរៀបរាប់នៅក្នុងក្របខណ្ឌនៃការលាតត្រដាងដោយបើកចំហអូស្ត្រាលី (Australian Open Disclosure Framework)។

# ករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (DUTY OF CANDOUR)

## សំណួរដែលគេតែងសួរជាញឹកញាប់



## សិទ្ធិរបស់អ្នក

### តើខ្ញុំអាចធ្វើអ្វីខ្លះ ប្រសិនបើខ្ញុំមិនយល់ស្របនឹងរបកគំហើញនៃការពិនិត្យសើរើឡើងវិញនោះ?

**A** អ្នកអាចទាក់ទងមនុស្សទំនាក់ទំនងចម្បង ឬមន្ត្រីទំនាក់ទំនងអ្នកប្រើប្រាស់ ដើម្បីចែករំលែកពីកង្វល់របស់អ្នក។ ប្រសិនបើបញ្ហានេះមិនអាចដោះស្រាយបានទេ អ្នកប្រហែលជាចង់ធ្វើបណ្ដឹងតវ៉ាជាមួយ៖

- សេវាកម្មសុខភាព
  - ស្នើសុំនិយាយទៅផ្នែកទទួលបន្ទុកបណ្ដឹងតវ៉ា
- ស្នងការទទួលបន្ទុកបណ្ដឹងតវ៉ាទាក់ទងនឹងសុខភាព
  - ហៅទូរសព្ទលេខ**1300 582 113** រវាងម៉ោង 9:30 ព្រឹក ដល់ម៉ោង 3:00 រសៀល ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ
  - **hcc.vic.gov.au/contact**
- ស្នងការទទួលបន្ទុកបណ្ដឹងតវ៉ាទាក់ទងនឹងសុខភាពផ្លូវចិត្ត
  - ហៅទូរសព្ទទៅលេខ**1800 246 054** ចន្លោះម៉ោង 9:00 ព្រឹក ដល់ 5:00 ល្ងាច ថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ
  - **www.mhcc.vic.gov.au/contact-us**
- តុលាការអ្នកពិនិត្យសាកសពរដ្ឋវិចថូរៀ (Coroners Court of Victoria)
  - ហៅទូរសព្ទលេខ**1300 309 519** រវាងម៉ោង 8.30 ព្រឹក ដល់ម៉ោង 5.00 ល្ងាច ថ្ងៃចន្ទ ដល់ថ្ងៃសុក្រ
  - **www.coronerscourt.vic.gov.au/families**

### ប្រសិនបើខ្ញុំចង់ធ្វើបណ្ដឹងតវ៉ា តើវាជាផ្នែកនៃដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor) ទេ?

**A** ទេ។ ការធ្វើបណ្ដឹងតវ៉ាគឺជាដំណើរការដាច់ដោយឡែកមួយចំពោះករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម **(Duty of Candor)**។

### តើខ្ញុំអាចស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់បានទេ ប្រសិនបើដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor) កំពុងកើតឡើង ឬបានចាប់ផ្ដើមហើយ?

**A** បាទ/ចាស បាន។ ករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម **(Duty of Candor)** មិនបញ្ឈប់អ្នកពីការស្វែងរកដំណោះស្រាយតាមផ្លូវច្បាប់នៅក្រៅដំណើរការនេះទេ។

### តើព័ត៌មានអ្វីខ្លះដែលខ្ញុំអាចប្រើប្រាស់បានពីដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor) នៅក្នុងដំណើការផ្លូវច្បាប់?

**A** ដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម **(Duty of Candor)** ធានាថាអ្នក ឬគ្រួសារ ឬអ្នកថែទាំរបស់អ្នកទទួលបាន៖

1. ការសុំទោស
2. អង្គហេតុនៃព្រឹត្តិការណ៍
3. ការពណ៌នាអំពីការឆ្លើយតបរបស់សេវាកម្មសុខភាពចំពោះព្រឹត្តិការណ៍នោះ (មានន័យថាអ្វីខ្លះដែលពួកគេបានធ្វើនៅពេលនោះ)
4. រាល់ជំហានណាមួយដែលសេវាកម្មសុខភាពបានចាត់វិធានការដើម្បីការពារកុំឱ្យកើតឡើងម្ដងទៀត។

មានតែការសុំទោសប៉ុណ្ណោះដែលត្រូវបានការពារពីការប្រើប្រាស់ក្នុងចំណាត់ការផ្លូវច្បាប់ ហើយមិនមែនជាការទទួលស្គាល់កំហុសនោះទេ។

ទោះយ៉ាងណាក៏ដោយ សេវាកម្មសុខភាពអាចអនុវត្តនូវ**ដំណើរការពិនិត្យសើរើឡើងវិញដែលមានការការពារ** ដើម្បីលើកទឹកចិត្តឱ្យមានការពិគ្រោះយោបល់ដោយបើកចំហ និងស្មោះត្រង់ជាមួយគ្រូពេទ្យគ្លីនិកដែលពាក់ព័ន្ធ ដែលនាំមកនូវអនុសាសន៍ និងរបកគំហើញដ៏រឹងមាំបន្ថែមទៀត។

បន្ទាប់មក ការការពារទាំងនេះនឹងការពារឯកសារជាក់លាក់មួយចំនួន រួមទាំងរបាយការណ៍ចុងក្រោយពីការប្រើប្រាស់ក្នុងចំណាត់ការផ្លូវច្បាប់ផងដែរ។ ដើម្បីដឹងបន្ថែមទៀត សូមសួរសេវាកម្មសុខភាពរបស់អ្នក ប្រសិនបើការពិនិត្យសើរើឡើងវិញនឹងត្រូវបានការពារ។

### តើមានអ្វីកើតឡើងប្រសិនបើសេវាកម្មសុខភាពមិនអនុលោមតតាមដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor)?

**A** រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងលេខាអាចពិចារណាលើការខកខានរបស់សេវាកម្មសុខភាពនោះ ក្នុងការបំពេញតាមដំណើរការករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម **(Duty of Candor)**។

អាស្រ័យលើចំនួន និងភាពធ្ងន់ធ្ងរនៃការខកខានរបស់សេវាកម្មសុខភាព រដ្ឋមន្ត្រីអាចចេញសេចក្ដីថ្លែងការណ៍មួយដែលមានឈ្មោះសេវាកម្មសុខភាពដែលពាក់ព័ន្ធនៅលើគេហទំព័ររបស់ក្រសួង ដោយបញ្ជាក់ថាសេវាកម្មសុខភាពនោះមិនបានអនុលោមតាមករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candor) ទេ។

### ដើម្បីស្វែងយល់បន្ថែមទៀតអំពីលក្ខខណ្ឌតម្រូវខាងផ្លូវច្បាប់នៃករណីយកិច្ចនៃភាពស្មោះត្រង់មិនលាក់លៀម (Duty of Candour)

**ចូលទៅកាន់៖**

**www.safercare.vic.gov.au/duty-of-candour-resources-for-patients-families-and-their-carers**

Safer Care Victoria